**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ៣៤២/២៣ ក. ស. ភ.

ថ្ងៃពុធ ១២កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលក្នុងការចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ជាលើកទី២ របស់ កំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា យោងសេចក្តីជូនដំណឹងលេខ ៤៣៩/២៣ ក.ស.ភ. ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ក.ស.ភ. បានបញ្ជាក់អំពីការពន្យារពេលក្នុងការផ្តល់ជូនរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

ដោយហេតុថា សវនករឯករាជ្យ KPMG បានតម្រូវឱ្យ ក.ស.ភ. ធ្វើការរាយការណ៍ឡើងវិញ (Restatement) ទៅលើគណនីមួយចំនួននៅក្នុងបញ្ជិកាគណនេយ្យ ដូចនេះ ក.ស.ភ. ត្រូវការចំណាយពេលវេលាបន្ថែមដើម្បីផ្តល់ជូនសវនករនូវឯកសារយោងពាក់ព័ន្ធ ក៏ដូចជាត្រូវការពេលវេលាដើម្បីពិភាក្សាជាមួយនឹងសវនករឯករាជ្យ BDO ដែលជាសវនករធ្លាប់បានធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ. នាពេលកន្លងមក។ ដូចនេះ **របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់ ក.ស.ភ. នឹងត្រូវបន្តពន្យារពេលជាលើកទី២ ក្នុងការចេញផ្សាយរហូតដល់ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ វិញ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម វិនិយោគិន និងសាធារណជន ជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨២៧ ៨០២ Email: ppapmpwt@online.com.kh